**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អគ្គស្នងការដ្ឋាននគរបាលជាតិ**
**ស្នងការដ្ឋាននគរបាលខេត្តកណ្ដាល**
លេខ:..៤៩៧..បេក

**សូមគោរពជូន**
**ឯកឧត្តម បណ្ឌិត គង់ សោភ័ណ្ឌ អភិបាលនៃគណៈអភិបាលខេត្តកណ្ដាល**

**ជាទីគោរពដ៏ខ្ពង់ខ្ពស់!**

**កម្មវត្ថុ** : ស្ដីសកម្មភាពយោធាការពារព្រំដែនខេត្តអានយ៉ាង(វៀតណាម) ប៉ុស្តិ៍៩២៥វិញសឿង បានរុះរើតង់ចាស់ដោយផ្លាស់ប្ដូរសាងសង់តង់ថ្មី (ជាជម្រករឹងមាំ)។

តបតាមកម្មវត្ថុខាងលើ ខ្ញុំមានកិត្តិយសសូមគោរពជម្រាបជូន ឯកឧត្តម អភិបាល នៃគណៈអភិបាលខេត្ត មេត្តាជ្រាប៖

នៅថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២០ វេលាម៉ោង១៧:០០នាទីល្ងាច កម្លាំងប៉ុស្តិ៍នគរបាលការពារព្រំដែនក្អមសំណចំនួន០៥នាក់ បានសហការជាមួយកម្លាំងយោធាការពារព្រំដែនកង៦០១ចំនួន០៧នាក់ និងលោកនាយប៉ុស្តិ៍នគរបាលរដ្ឋបាលក្អមសំណ បានចុះទៅពិនិត្យនៅចំណុចទីតាំងតង់ចាស់របស់យោធាការពារព្រំដែនវៀតណាម ប៉ុស្តិ៍៩២៥វិញសឿង នៅនិយាមការ514575-1206948 ភូមិគូរី ឃុំក្វុឡុក ស្រុកទិនប៊ូ ខេត្តអានយ៉ាង ទល់នឹងភូមិក្អមសំណក្រោម ឃុំក្អមសំណ ស្រុកលើកដែក ខេត្តកណ្ដាល បានជួបភាគីវៀតណាមកំពុងសាងសង់តង់ថ្មី (ជាជម្រករឹងមាំ) ដោយសាងសង់អំពីឈើ សសរថ្ម កម្ពស់៣ម៉ែត្រ ទំហំ៥ម៉ែត្រx៤ម៉ែត្រ ដំបូលប្រក់ស័ង្កសី ដោយឃ្លាតពីខ្សែបន្ទាត់ព្រំដែនដែលយើងគ្រប់គ្រងបច្ចុប្បន្នចម្ងាយប្រមាណ១២០ម៉ែត្រ។

ទន្ទឹមនោះ កម្លាំងទាំង០៣អង្គភាពខាងលើ បានទៅជួបជាមួយប្រធានប៉ុស្តិ៍៩២៥វិញសឿង ដើម្បីទាមទារឲ្យភាគីវៀតណាមបញ្ឈប់សកម្មភាពសាងសង់តង់ថ្មីខាងលើនេះ។ ប៉ុន្តែភាគីវៀតណាមបានបញ្ជាក់ថាគេធ្វើតាមបញ្ជាថ្នាក់លើរបស់គេ ហើយថ្នាក់លើរបស់គេមានគម្រោងសាងសង់តង់ថ្មី(ជាជម្រករឹងមាំ) ចំនួន០៤គោលដៅលើ១០គោលដៅចាស់ដែលមានស្រាប់។

លុះនៅព្រឹកថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២០ លោកអភិបាលស្រុកលើកដែក និងកម្លាំងពាក់ព័ន្ធបានចុះត្រួតពិនិត្យនៅទីតាំងខាងលើនេះម្ដងទៀត និងបានសំណូមពរឲ្យភាគីវៀតណាមបញ្ឈប់ការសាងសង់ជាបន្ទាន់។ ប៉ុន្តែភាគីវៀតណាម មិនព្រមឯកភាពបញ្ឈប់ការសាងសង់នោះឡើយ។

សេចក្ដីដូចបានគោរពជម្រាបជូនខាងលើ សូម ឯកឧត្តម អភិបាល នៃគណៈអភិបាលខេត្ត មេត្តាទទួលជ្រាប និងសុំអនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់។

សូមឯកឧត្តម មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

ថ្ងៃ ពុធ ៨កើត ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស២៥៦៤
កណ្ដាល ថ្ងៃទី២៦ ខែ សីហា ឆ្នាំ២០២០
**ស្នងការ**

ស្នងការដ្ឋាន នគរបាល ខេត្ត កណ្ដាល

ឧត្តមសេនីយ៍ទោ. ឈឿន_សុចិត្ត